

# និទានកថា អំពីឧបករណ៍ «អង្គួច» របស់ប្រទេសកម្ពុជា

ឯកសារចងក្រងអំពីឧបករណ៍តន្ត្រីដ៏កម្រមួយ រួមទាំងអ្នកធ្វើ និង
អ្នកផ្ចាត់ឧបករណ៍កម្រនោះ

# Stories of Cambodian “Angkuoch”

Documenting a rare musical instrument,
its makers and players







«ខ្ញុំសប្បាយចិត្តណាស់ដែលបានចែករំលែកចំណេះដឹងអំពីអង្កួច ទៅកាន់មនុស្សដទៃទៀត។ ពេលដែលបានបង្ហាញពីរបៀបធ្វើអង្កួចបែបនេះ ខ្ញុំត្រេកអរណាស់។ ពិតជាត្រេកអរមែន! ខ្ញុំមានអារម្មណ៍សាទរជាមួយនឹងគម្រោងនេះ ព្រោះខ្ញុំយល់ឃើញថា ក្រុមអ្នកស្រាវជ្រាវ នឹងយកព័ត៌មាននេះ ទៅផ្សព្វផ្សាយឱ្យបានកាន់តែទូលំទូលាយ ដើម្បីឱ្យបងប្អូនដឹងអំពីប្រវត្តិរបស់អង្កួច! »

**–ប្រសាសន៍របស់ព្រឹទ្ធាចារ្យអ្នកធ្វើអង្កួច ប៊ិន សុង**

---

*"I am very happy that I get to share my knowledge about Angkuoch with other people. When I can demonstrate how to make Angkuoch, I am very excited. Extremely excited! I feel happy about this project because I think the research team will spread this information widely. To let other people know more about Angkuoch!"*

***–Bin Song, Angkuoch maker***

ទោះបីជាឧបករណ៍«អង្គួច»ត្រូវបានអ្នកស្រាវជ្រាវរកឃើញថាមានច្រើនប្រភេទនៅទូទាំងពិភពលោកក៏ដោយ ប៉ុន្តែ ប្រភេទអង្គួចរបស់កម្ពុជា នៅតែមានលក្ខណៈពិសេសប្លែកពីគេ។ ហើយ អង្គួច គឺជាចំណែកនៃមរតកវប្បធម៌កម្ពុជា ដ៏មានតម្លៃមួយថែមទៀតផង។

សព្វថ្ងៃនេះ អង្គួច និងទំនៀមទម្លាប់នៃការផ្ទាត់ ឬលេង ឧបករណ៍តន្ត្រីដ៏កម្រនេះ កំពុងតែហៀបនឹងបាត់បង់ ដែលតម្រូវឱ្យអភិរក្សយ៉ាងឆាប់បំផុត។ ការផ្លាស់ប្តូរនៃបទដ្ឋានសង្គម និងវប្បធម៌របស់កម្ពុជានាពាក់កណ្តាលសតវត្សចុងក្រោយនេះ បូករួមនឹងការបំផ្លិចបំផ្លាញក្នុងសម័យខ្មែរក្រហម បានបន្សល់មនុស្សតែប៉ុន្មាននាក់ចុងក្រោយប៉ុណ្ណោះដែលចេះពីរបៀបធ្វើ និងផ្ទាត់អង្គួច។

ដោយមានការគាំទ្រពីកម្មវិធី ចំណេះដឹង ស្តីអំពីសម្ភារៈដែលជិតបាត់បង់ របស់សារមន្ទីរនៃចក្រភពអង់គ្លេស និងអង្គការយូណេស្កូប្រចាំនៅប្រទេសកម្ពុជា ពួកយើងបានចងក្រងឯកសារដ៏មានតម្លៃ អំពីឧបករណ៍អង្គួច និងការធ្វើអង្គួច នៅក្នុងខេត្តសៀមរាប។ គោលបំណងនៃការចងក្រងនេះ គឺដើម្បីជួយអភិរក្សចំណេះដឹងដ៏មានតម្លៃមួយនេះ ទុកជាប្រយោជន៍ នឹងជាការកំសាន្តដល់មនុស្សជំនាន់នេះ និងជំនាន់ក្រោយៗទៀត។

នៅក្នុងកូនសៀវភៅនេះ យើងខ្ញុំបានចែករំលែករឿងរ៉ាវដ៏កម្រខ្លះៗជុំវិញរឿងដ៏អស្ចារ្យជាច្រើនដែលយើងបានរៀនសូត្រពីគម្រោងនេះ។ ជាមួយគ្នានេះដែរ ពួកយើងក៏បានផលិតវីដេអូឯកសារអំពី អង្គួច អ្នកធ្វើ និងអ្នកផ្ទាត់អង្គួច ដែលអាចឱ្យអស់លោកអ្នកទស្សនាបានដោយសេរីតាមប្រព័ន្ធអនឡាញ (រកមើលតំណភ្ជាប់នៅលើទំព័រចុងក្រោយ)។ យើងខ្ញុំសូមអញ្ជើញអស់លោកអ្នកចូលរួមទស្សនាទាំងអស់គ្នា ឱ្យបានច្រើនកុះករ។

យើងខ្ញុំសូមថ្លែងអំណរគុណដល់អ្នកធ្វើ និងអ្នកផ្ទាត់ ឬលេងអង្គួច ដែលចូលរួមជួយលើគម្រោងនេះ ពោរពេញដោយក្តីអំណរ ក៏ដូចជាចែករំលែកចំណេះដឹង និងជំនាញដល់ពួកយើងខ្ញុំ។ អ្នកទាំងអស់នោះ រួមមាន៖ លោកព្រឹទ្ធាចារ្យ ប៊ីន សុង, លោកព្រឹទ្ធាចារ្យ ក្រាក់ ជី, លោក ជី មុនីវង់ និងលោក ជី ចិន។ ឆ្លៀតក្នុងឱកាសនេះដែរ យើងខ្ញុំក៏សូមអរគុណដល់លោកយាយ ឡាវ ម៉ិច, អ្នកនាង គើយ លក្ខិណា និងលោក គើយ រដ្ឋា និងក្រុមគ្រួសាររបស់លោកតា ម៉ុង គើយ។ ដោយសារតែមានការអនុញ្ញាតពីក្រុមគ្រួសារនេះហើយ ទើបយើងខ្ញុំ អាចមានឱកាសចងក្រងរឿងរ៉ាវរបស់ពួកគាត់ក្នុងកូនសៀវភៅមួយក្បាលនេះ ដើម្បីថែរក្សា ការពារ និងចែករំលែក។

យើងខ្ញុំសង្ឃឹមថា លទ្ធផលនៃគម្រោងនេះនឹងញ៉ាំងចិត្តប្រជាជនកម្ពុជា និងប្រជាជនជុំវិញពិភពលោក ឱ្យងាកមកផ្តល់តម្លៃ និងយល់ដឹងអំពីសារៈសំខាន់នៃឧបករណ៍អង្គួចនាពេលបច្ចុប្បន្ន និងទៅថ្ងៃអនាគត។

**ខាត់ធីរីន ហ្គ្រាន (សាកលវិទ្យាល័យហ្គ្រីហ្វហ្វីធ ប្រទេសអូស្ត្រាលី)**
**ស៊ុង សេង (អង្គការសិល្បៈខ្មែរអមតៈ)**
**ប៉ាទ្រីក ឃើសសាឡេ (អង្គការសិល្បៈខ្មែរអមតៈ)**

**មិថុនា ២០២០**

Although the musical instrument popularly known as the “Jew’s Harp” is found in many countries around the world, the Cambodian version is unique. Called Angkuoch (pronounced something like “Aarng-koo-oy”) in Khmer, it is a precious part of Cambodia’s living cultural heritage.

Nowadays, Angkuoch and its associated practices are in need of urgent safeguarding. Social and cultural shifts in Cambodia over the last half-century, including the devastation of the Khmer Rouge era in the 1970s, mean that only a handful of people still know how to make and play Angkuoch.

Supported by the Endangered Material Knowledge Program of the British Museum (UK) and by UNESCO (Cambodia), in early 2020 we documented Angkuoch and Angkuoch-making as it is practiced in Siem Reap Province in northern Cambodia. Our aim was to help preserve this rich knowledge for the benefit and pleasure of present and future generations.

In this booklet we share with you only a few of the many wonderful things we learnt through this project. We have also created a video documentary about Angkuoch and its makers and players, which is freely available online (see link on last page of this brochure). We warmly invite you to have a look.

We are grateful to the Angkuoch makers and players who participated in this project, who so generously shared with us their knowledge and skills: BIN Song, SON Soeun, KRAK Chi, CHI Monivong, and CHI Chen. We also acknowledge LAV Mech, KOEUY Leakhena, KOEUY Reatha and the family of MONG Koeuy, whose beautiful story we share here too, with their kind permission.

We hope that this project inspires people in Cambodia and around the world to appreciate the beauty and importance of Angkuoch, now and long into the future.

*Catherine Grant (Griffith University, Australia)*
*Seng Song (Cambodian Living Arts)*
*Patrick Kersale (Cambodian Living Arts)*

**June 2020**





«ខ្ញុំសូមប្រាប់ដល់ក្មេងៗជំនាន់ក្រោយថា ធ្វើយ៉ាងណា សូមមេត្តាលេងអង្កួចនេះឱ្យបានគ្រប់ៗគ្នា ។ រៀនលេងឱ្យបានទាំងអស់គ្នា! បើមានគ្រូណាចេះផ្ចាត់ ឬចេះលេង ត្រូវទៅរៀនពីគេដើម្បីឱ្យបានចេះគ្រប់ៗគ្នា! សូមឱ្យវាបន្តទៅមុខទៀត កុំឱ្យវាបាត់បង់!»

**–ប៊ិន សុង**

*"I want to tell people in the next generation that no matter what, you should certainly play this Angkuoch. Learn to play! If there is a teacher who teaches how to play and make it, you should go to learn. Keep it alive! Don't let it be lost!"*

***–Bin Song***

លោកព្រឹទ្ធាចារ្យ ប៊ិន សុង (កើតឆ្នាំ ១៩៤២) ហើយក៏ប្រហែលជានៅសល់តែគាត់ម្នាក់ទេ ដែលចេះធ្វើ អង្គួចដែកនៅក្នុងប្រទេសកម្ពុជា។

ព្រឹទ្ធាចារ្យ ប៊ិន សុង បានស្គាល់អង្គួចដែកជាលើកដំបូងតាំងតែពីគាត់នៅក្មេង តាមរយៈបុរសជនជាតិកួយម្នាក់ដែលដើរកាត់ភូមិរបស់គាត់។ ដោយសារតែចង់ស្គាល់ច្បាស់ពីឧបករណ៍មួយនេះ គាត់បានរៀនលេងដោយខ្លួនឯង និងរៀនពីរបៀបធ្វើនៅពេលក្រោយៗមកទៀត។ ទោះបីគាត់នៅក្មេងក៏ដោយ តែដោយសារតែមានជំនាញធ្វើអង្គួចនេះច្បាស់ បណ្ដាលឱ្យមនុស្សជាច្រើនចាប់ផ្ដើមស្គាល់គាត់។

ដូចគ្នានឹងសិល្បករក្នុងប្រទេសកម្ពុជាដែរ ព្រឹទ្ធាចារ្យ ប៊ិន សុង បានឈប់ធ្វើឧបករណ៍តន្ត្រីមួយប្រភេទនេះ នៅគ្រាដែលខ្មែរក្រហមក្ដោបក្ដាប់អំណាចទាំងស្រុងនាកំឡុងឆ្នាំ ១៩៧៥ ។ នៅពេលដែលក្រុមស្រាវជ្រាវនៃគម្រោងនេះទៅជម្រុញលើកទឹកចិត្តគាត់ឱ្យធ្វើអង្គួចដែកឡើងវិញនៅចុងឆ្នាំ ២០១៩ គាត់ក៏បានប្រាប់ថា គាត់ឈប់ធ្វើឧបករណ៍នេះ ប្រហែលហាសិបឆ្នាំទៅហើយ។

ពីដំបូង ព្រឹទ្ធាចារ្យ ប៊ិន សុង រួញរាមិនចង់ទទួលសំណូមពរពីយើងខ្ញុំនោះទេ។ គាត់ព្រួយបារម្ភថា ភ្នែកគាត់ចាប់ផ្ដើមខ្សោយទៅៗ មិនអាចធ្វើអង្គួចដែកទៀតបាន។ លើសពីនោះទៀត ធ្មេញគាត់បាក់សឹងអស់ ដូច្នេះគាត់មិនអាចសាកល្បងលេងឧបករណ៍ដែលគាត់ធ្វើនោះបានទេ។ តែទោះជាយ៉ាងណា គាត់យល់ព្រមចូលរួមជួយក្នុងគម្រោងនេះ។ ក្រោយមក គាត់បានប្រាប់យើងខ្ញុំថា៖ «ខ្ញុំជរាណាស់ហើយ។ តែបន្ទាប់ពីគិតយូរៗទៅខ្ញុំយល់ថា វាពិតជាមានសារៈសំខាន់ណាស់ រឿងផ្ទេរចំណេះដឹងនេះទៅកាន់ក្មេងជំនាន់ក្រោយ។ ប្រសិនបើខ្ញុំមិនចែករំលែក តើនរណានឹងចែករំលែកចំណេះទាំងអស់នេះបាន។ ប្រសិនបើខ្ញុំមិនធ្វើពេលនេះ អញ្ចឹងពេលណាទើបសាកសម?»

សារមន្ទីរនៃចក្រភពអង់គ្លេស នឹងរក្សាអង្គួចដែក ព្រមទាំងវីដេអូដែលបង្ហាញគ្រប់ជំហាននៃការធ្វើអង្គួចដើក ដែលលោកព្រឹទ្ធាចារ្យ ប៊ិន សួង បានធ្វើនេះ ទុកក្នុងសមុច្ច័យ។ ខណៈពេលដែលព្រឹទ្ធាចារ្យ ប៊ីន សុង សំដែងនូវភាពរីករាយដែលដឹងថាមនុស្សជុំវិញពិភពលោកនឹងអាចរៀនពីអង្គួចដែក គាត់ក៏មិនភ្លេចផ្ដាំផ្ញើទៅកាន់ក្មេងៗជំនាន់ក្រោយនៅក្នុងស្រុកថា៖ «សូមកុំបោះបង់ឧបករណ៍អង្គួចនេះ! នេះគឺជាវប្បធម៌ និងកេរតំណែលរបស់យើង!»

Bin Song (b. 1942) may be the only living person who still knows how to make the iron Cambodian Angkuoch, “Angkuoch Daek”.

Known as “Ta Song” (“Grandpa Song”), Bin Song was first introduced to Angkuoch Daek as a child, by a man from the neighbouring Kuy ethnic community. Intrigued, he taught himself how to play it, and eventually to make it too. As a young man, he became known for his skills with the Angkuoch.

Like artists all over Cambodia, Bin Song stopped making instruments and music when the despotic Khmer Rouge came to power in 1975. When the research team for this project encouraged him in late 2019 to make an Angkuoch Daek, he had not made an instrument for nearly fifty years.

At first, Ta Song hesitated to accept our invitation. He was concerned that his eyesight was no longer up to the task. Moreover, he had lost his teeth, so couldn’t test the instrument out as he made it. Yet he agreed. Later he told us: “I’m getting old now, and when I reflected on it, I realised it was important to pass this knowledge on to the next generation. If I don’t, who will? If not now, when?”

The British Museum will keep in its collection the Angkuoch Daek that Bin Song made for this project, along with video documentation showing every step of the process. While Ta Song is happy that people from all around the world will have a chance to learn about Angkuoch Daek, his foremost message is to young Cambodians: “Do not give up on Angkuoch! This is our culture and heritage!”

ANGKUOCH

ព្រឹទ្ធាចារ្យ សុន សឿន និង ប៊ិន សុង (កើតនៅអំឡុងឆ្នាំ ១៩៤២ ដូចគ្នា) និងក្លាយជាមិត្តសម្លាញ់នឹងគ្នាតាំងតែពីយូរយារណាស់មកហើយ។ ពួកគាត់ទាំងពីរនាក់បានធំដឹងក្តីនៅអំឡុងឆ្នាំ ១៩៥០ និង ១៩៦០ ស្ថិតក្នុងភូមិព្រះគោ ខេត្តសៀមរាប។ ហើយក្រោយមកទៀត ពួកគាត់ក៏បានសាងផ្នួសក្នុងពេលជាមួយគ្នាថែមទៀតផង។

កាលនៅពីក្មេង ពេលដែលលោកព្រឹទ្ធាចារ្យ ប៊ិន សុង ចាប់ផ្តើមចេះផ្លាត់ ឬលេង និងធ្វើអង្កួចដែកនេះ ព្រឹទ្ធាចារ្យ សុន សឿន ក៏បានចាប់ចិត្តលេងអង្កួចដែកនេះជាមួយគ្នាផងដែរ។ ហើយក្រោយមក គាត់ក៏ចេះលេងឧបករណ៍តន្ត្រីនេះយ៉ាងស្ទាត់ជំនាញ។ បើតាមភាសាតំបន់ ឧបករណ៍នេះ ត្រូវបានអ្នកស្រុកឱ្យឈ្មោះថា «សត្វក្ងោក» ដោយសារតែរូបរាងរបស់វាដូចសត្វក្ងោក ដែលជាប្រភេទសត្វបក្សី។ កាលនោះ កុមារទាំងពីរនាក់នេះ តែងតែដាក់អង្កួចក្នុងហោប៉ៅជាប់ជាប្រចាំ ដើម្បីផ្លាត់កំសាន្តនៅពេលណាដែលពួកគេដើរលេងតាមភូមិក្បែរៗនោះ។

លុះពេលដែលក្មេងប្រុសទាំងពីរនាក់នេះធំដឹងក្តីឡើង ប្រុសៗជំទង់ជំនាន់នោះ ក៏និយមប្រើអង្កួច  ដើម្បីលែបខាយសម្តី (ញ៉ែ) ដាក់នារីៗ។ ពាក្យពេចន៍ទាំងឡាយអាចនឹងរាយតាមអង្កួចនេះបាន គ្រាន់តែថា ត្រូវការពេលបន្តិចដើម្បីឈ្វេងយល់ពីភាសារបស់អង្កួច។ ក្នុងយុវភាព កម្លោះសុង នឹងសឿន តែងតែប្រើអង្កួចដើម្បីបំពេញបំណងមួយនេះ។

ក្រៅពីមាននាទីជាឧបករណ៍នាំពាក្យពេចន៍អន្ទងចិត្តហៅនារីជាទីស្រលាញ់របស់គេ អង្កួចតែងតែត្រូវគេផ្លាត់ប្រគំជាភ្លេងសម្រាប់ចម្រៀង «ព្រឹន»។ ហើយបទចម្រៀងដែលមានប្រជាប្រិយបំផុតនាពេលនោះ គឺបទ «សន្ទូច»។ អ្នកលេងអង្កួចជាច្រើន មិនថាស្រី ឬប្រុសទេ អាចចូលរួមច្រៀង និងរាំកំសាន្តទាំងអស់គ្នា ដោយផ្លាតអង្កួចដៃម្ខាង និងរាំដៃម្ខាង។ មនុស្សម្នាឯទៀតក៏អាចចូលរួមលេង និងស្តាប់អង្កួចបានដែររាល់ពេលមានពិធីបុណ្យចូលឆ្នាំ ឬបុណ្យភូមិផ្សេងៗ។

Son Soeun and Bin Song (both born 1942) are lifelong friends. In the 1950s and '60s, they grew up together in Preah Ko village in Siem Reap Province, even entering the monkhood together for a time.

When the young Bin Song began to make and play Angkuoch Daek, Soeun became intrigued by the instrument too. Over time, he learnt to play proficiently. In the local lingo, the instrument was called "Angkuoch Peacock" on account of its shape. The two boys would often slip an Angkuoch Peacock in their pockets to play for pleasure whenever they chose.

When the two boys were growing up, boys and young men often used Angkuoch to flirt with girls and young women. Words can be 'spoken' through the instrument, although it takes some practice to interpret them. In this way, young people developed a secret language – the language of Angkuoch. As youths, Song and Souen would often use the Angkuoch for this purpose!

In addition to its role in wooing potential lovers, Angkuoch traditionally accompanied "Prern", a type of folksong. An especially popular Prern song was "Santouch". Several Angkuoch players – both male and female – could join in, first singing and dancing together, then playing Angkuoch with one hand and dancing with the other. People also enjoyed playing and listening to Angkuoch during festivals or special celebrations.







«ខ្ញុំកាលពីដើម ពេលដែលនៅកំលោះ ខ្ញុំតែងតែដើរលេងផ្ទះនារីៗរាល់ពេលយប់។ បើទៅដល់ផ្ទះអ្នកដែលខ្ញុំស្រឡាញ់ ហើយពេលទៅដល់ គេដេកលក់បាត់ ខ្ញុំផ្លុំដើម្បីហៅនាង។ ពេលដែលហៅយូរៗ នាងក៏ភ្ញាក់ ហើយក្រោកមកជួបខ្ញុំ។ ហើយពួកយើងក៏អង្គុយលេងជាមួយគ្នា។ ខ្ញុំអាចហៅមកជួបកន្លែងណាក៏បានដែរ ឱ្យតែនាងបានឮសំឡេងអង្គួចនេះ។»

**-សុន សឿន**

*"When I was a bachelor, I went to visit the houses of girls at night. When I reached my lover's house, if she was already asleep, I played to call her. If I kept calling, she would wake up and come to meet me. And then we sat together. I could call her to meet me wherever I wanted as long as she heard the sound of my Angkuoch."*

***-Son Soeun***

«សន្ទូចសំតង អារ៉ែងកញ្ញែបួ! ឈរអែបក្បៀនទឹក ចែកស្រាបងផឹក បងរាំឱ្យមើល! សន្ទូចបងមួយ បងយកទៅចង ក្រពើខាំបង ខាំដាច់ថ្នេរខោ! អ្នកណាប៉ារ៉ៅៗ ដេរខោឱ្យបង!»

**-រំលឹកទំនុកចម្រៀងបទ «សន្ទូច» ដោយលោកគ្រូអាចារ្យ ប៊ិន សុង»**

*"Standing near the water pond, if you share with me your rice wine, I will dance for you to see, my dear. I take my only fish-hook, to tie it on. The crocodile bites me, and the stitching of my pants unravels! Oh those who are beautiful, come to sew up my pants!"*

***-Lyrics of Prern folksong, as recalled by Bin Song***

លោក ក្រាក់ ជី (កើតឆ្នាំ ១៩៥០) ជាកសិករ និងជាអ្នកធ្វើអង្កួចមកពីភូមិស្រះស្រង់ ដែលនៅជិតបង្អើយនឹងអង្គរវត្ត។ លោកនៅតែដិតដាមនឹងអនុស្សាវរីយ៍កាលពីកុមារ គឺរាល់ពេលដែលឪពុករបស់លោកផ្ទាត់អង្កួចលំហែអារម្មណ៍នាពេលល្ងាច។ គាត់ក៏នៅចាំដែរថា ក្មេងៗនៅជំនាន់នោះទិញអង្កួចឫស្សីពីអ្នកធ្វើអង្កួចតាមភូមិ ដើម្បីយកទៅលក់ឱ្យភ្ញៀវទេសចរណ៍ដែលមកកំសាន្តនៅតំបន់អង្គរ។

ចំពោះអង្កួចដែកវិញ កម្លោះៗចូលចិត្តផ្ទាត់វាចែចង់ស្រីៗដែលគេពេញចិត្ត។ លោក ជី ក៏នៅចាំរឿងដាក់ក្រមួនស្នេហ៍នៅលើឧបករណ៍នេះ ដើម្បីធ្វើឱ្យប្រាកដថា វិធីអន្ទងចិត្តដោយប្រើអង្កួចលាបក្រមួនស្នេហ៍នេះ មានប្រសិទ្ធភាពខ្ពស់។

នៅពាក់កណ្តាលឆ្នាំ ១៩៩០ លោក ក្រាក់ ជី មានចំណាប់អារម្មណ៍ធ្វើអង្កួច។ កូនប្រុសគាត់ លោក ជី ចិន ធ្លាប់ទិញអង្កួចពីអ្នកធ្វើអង្កួចដ៏ល្បីឈ្មោះម្នាក់ គឺលោកតា ម៉ុង គើយ ដែលរស់នៅភូមិព្រះដាក់។ ហើយគាត់ក៏យកអង្កួចដែលទិញបាននោះ ទៅលក់ឱ្យភ្ញៀវទេសចរណ៍។

តាមការអង្កេតលើការធ្វើអង្កួចរបស់លោកតា ម៉ុង គើយ លោក ក្រាក់ ជី ក៏សម្រេចចិត្តថានឹងរៀនធ្វើឧបករណ៍នេះដែរ។ ផ្នែកមួយដែលជម្រុញឱ្យគាត់ធ្វើឧបករណ៍នេះ គឺរឿងបង្កើតប្រាក់ចំណូល។ ហើយផ្នែកមួយទៀតគឺគោលបំណងដែលចង់ឱ្យប្រពៃណីតពីដូនតា នៅបន្តរស់រានទៅថ្ងៃមុខ។

សព្វថ្ងៃនេះ ក្រៅពីធ្វើស្រែចម្ការ លោក ក្រាក់ ជី ក៏មានតួនាទីជាមេភូមិផងដែរ។ ដូច្នេះហើយ គាត់មិនសូវមានពេលច្រើនមកធ្វើអង្កួចដូចពេលមុនៗនោះទេ។ ប៉ុន្តែ ដើម្បីធ្វើឱ្យប្រាកដថា ទំនៀមទម្លាប់នេះនៅតែអាចបន្តទៅមុខបាន គាត់បានបង្រៀនកូនប្រុស និងចៅប្រុសៗគាត់ពីរបៀបធ្វើអង្កួច។ ឥឡូវនេះ ឱ្យតែបានកាន់អង្កួចនៅក្នុងដៃម្តងណា គាត់នឹករឭកដល់ឪពុកគាត់ម្តងហ្នឹង។

Krak Chi (b. 1950) is a rice farmer and bamboo Angkuoch-maker from Srah Srong village, a stone's throw from the world-famous temple complex of Angkor Wat. Chi has childhood memories of his father playing Angkuoch in the evenings for pleasure. Chi also remembers local children buying Angkuoch Russey (bamboo Angkuoch) from instrument-makers in the village, then selling the instruments on to tourists at the nearby Angkor temples.

As with the iron Angkuoch Daek, boys and young men liked to use Angkuoch Russey to woo lovers. Krak Chi remembers an old custom of putting 'charming wax' on the instruments to make sure that any advances that were made via the Angkuoch were irresistible.

In the mid-1990s, Krak Chi began to take an interest in Angkuoch-making. His young son Chi Chen used to buy Angkuoch Russey from the famous Angkuoch maker Mong Koeuy in neighbouring Preah Dak village, and then sell them on to tourists.

Watching Mong Koeuy make the instruments, Krak Chi decided to learn too. He was motivated partly by the prospect of a modest income from selling the instruments, and partly by the desire to keep alive the tradition of his ancestors.

These days Krak Chi doesn't have much time for Angkuoch-making because of his rice-farming and because he is the head of his village. But to ensure the tradition continues, he has taught his sons and grandsons to make Angkuoch. Still today, when Krak Chi holds an Angkuoch in his hands, he thinks of his father.





«គេលេងអង្គួចនៅតាមផ្ទះគេ។ ថ្ងៃណាគេទំនេរ គេក៏កាន់ទៅផ្ទាត់នៅតាមវាលស្រែជាដើម។ បើគេនៅក្បែរស្រះស្រង់ គេយកទៅផ្ទាត់នៅក្បែរមាត់ស្រះស្រង់។ »
**-ក្រាក់ ជី**

*"People played Angkuoch in their houses. When they were free, sometimes they brought it to the rice field and played it right there. If they lived close to Sras Srong lake, they brought it to play around there."*
***-Krak Chi***

«កម្លោះក្រមុំញ៉ែគ្នានឹងអង្គួចកាលពីសម័យមុន វាដូចនឹងយើងសព្វថ្ងៃដែរ ដែលប្រើទូរស័ព្ទទាក់ទងគ្នា។ ប៉ុន្តែពេលនោះ គេប្រើអង្គួចដើម្បីទាក់ទងគ្នា។ »
**-ក្រាក់ ជី**

*"Boys and girls flirted with each other through the Angkuoch. In this present generation, people use the phone to talk to each other – but at that time they used the Angkuoch."*
***-Krak Chi***



កាលពីក្មេង លោក ជី ចិន (កើតឆ្នាំ ១៩៨៨) បានដើរលក់អង្គួចឫស្សីឱ្យភ្ញៀវទេសចរណ៍នៅប្រាសាទតាព្រហ្ម ដែលស្ថិតនៅមិនឆ្ងាយប៉ុន្មានពីភូមិស្រះស្រង់ដែលជាភូមិគាត់។ ក្រោយធំដឹងក្តី លោក ចិន បានក្លាយជាអ្នកផ្លុំអង្គួចដ៏ប៉ិនប្រសព្វ និងជាអ្នកលក់ឧបករណ៍តន្ត្រីមួយនេះ ដ៏ជោគជ័យម្នាក់ថែមទៀតផង។

ដោយសារតែកំណើននៃការលក់របស់ លោក ចិន ចេះតែកើនឡើងជាលំដាប់ និងដោយនឹករឭកដល់ឪពុកខ្លួនដែលជាអ្នកលេងអង្គួចឫស្សីដ៏មានទេពកោសល្យផងនោះ លោក ក្រាក់ ជី ដែលជាឪពុករបស់ លោក ចិន (បានរៀបរាប់នៅទំព័រមុន) ក៏បានចាប់ផ្តើមរៀនធ្វើឧបករណ៍នេះឡើង។ ក្រោយមកទៀតគាត់ក៏បានបង្រៀន លោក មុនីវង់ ដែលជាកូនប្រុសខ្លួនឱ្យចេះជំនាញនេះដែរ។ មិនយូរប៉ុន្មាន លោក មុនីវង់ (កើតក្នុងឆ្នាំ ១៩៩០) បានច្នៃរបៀបធ្វើថ្មីៗបន្ថែមទៀត ដែលរបៀបខ្លះត្រូវឪពុករបស់លោកយកគម្រូតាមវិញក៏មានដែរ។

ចំណេរក្រោយមក លោក ចិន និង មុនីវង់ ត្រូវគេស្គាល់ថា ជាអ្នកផ្លុំអង្គួច និងលេងអង្គួចឫស្សីជំនាន់ថ្មី។ ប៉ុន្តែ នៅប៉ុន្មានឆ្នាំចុងក្រោយនេះ ពួកគាត់សង្កេតឃើញថា ភ្ញៀវទេសចរណ៍មិនស្គាល់អង្គួចដូចពីមុនឡើយ។ មនុស្សមកទិញអង្គួច ចេះតែស្ងៀមទៅៗ បណ្តាលឱ្យពួកគាត់ចាប់ផ្តើមពិបាករកប្រាក់មកផ្គត់ផ្គង់គ្រួសារ។

ចូលដល់វ័យសាមសិប លោក ចិន និងលោក មុនីវង់ បានចូលបម្រើការងារពេញម៉ោង ហើយពួកគេមិនសូវមានពេលទំនេរមកធ្វើអង្គួចដូចមុននោះឡើយ។ តែទោះជាយ៉ាងណា ពួកគេសប្បាយចិត្តដែលឪពុកគេនៅបន្តបង្រៀនចៅៗពីរនាក់ទៀតពីរបៀបធ្វើអង្គួច។ ពួកគេសង្ឃឹមថា ទំនៀមទម្លាប់ធ្វើអង្គួចនៅក្នុងគ្រួសារគេនឹងនៅតែបន្ត និងបន្តរីកចម្រើនទៅមុខជាលំដាប់។ ហើយមនុស្សគ្រប់វ័យនឹងនៅតែស្គាល់ ហើយអាចបន្តរីករាយផ្លុំអង្គួចនេះម្តងទៀត។

As a young boy, Chi Chen (b. 1988) would sell Angkuoch Russey to tourists at the famous Ta Prohm temple near his village Srah Srong. By his teenage years, Chen had become a proficient player and successful seller of the instruments.

Encouraged by Chen's success, and recalling that his own father used to play Angkuoch Russey, Chen's father Krak Chi (featured on the previous pages) soon began to make the instruments. Then he taught his son Monivong too. Chi Monivong (b. 1990) later introduced some clever innovations to the making technique, some of which his father has since adopted.

The brothers Chen and Monivong soon became known as new-generation makers and players of Angkuoch Russey. However, they subsequently found that fewer tourists knew about Angkuoch. Consequently, fewer people were buying it and it became harder to earn an income by making and selling it.

Now Chen and Monivong are in their early thirties with full-time jobs, and they no longer have much free time for Angkuoch-making. However, they are happy that their father is teaching his two young grandsons how to make Angkuoch. They hope that the family tradition continues and develops, and that people of all ages will know and enjoy Angkuoch in the future.



«ពីមុន ពេលដែលគាត់ពុះឫស្សីហើយ គាត់ហាល
រយៈពេលពីរទៅបីថ្ងៃ ឬមួយថ្ងៃកន្លះ។ តែសម្រាប់ខ្ញុំ
ដូចដែលបានធ្វើឱ្យបងមើលមុននេះ ខ្ញុំជ្រើសរើស
ការរោលនឹងភ្លើង ដោយសារតែវាលឿន។ ឥឡូវ
ឪពុកខ្ញុំធ្វើតាមខ្ញុំដែរ។ »
**-ជី មុនីវង្ស (រូបខាងក្រោម)**

*"Once Angkuoch-makers had chopped the bamboo into pieces, they used to dry it on a board in the sun for one or two days. My father used to do this too. But I choose to dry the bamboo by smoking it over the fire, because it is faster. Now my father copies my way of making."*
***–Chi Monivong (below)***

«មនុស្សភាគតិចណាស់ដែលស្គាល់ តែមិនស្គាល់
មានភាគច្រើន។ អ្នកដែលស្គាល់ ភាគច្រើនជា
មនុស្សចាស់។ ពេលចាស់ៗឃើញខ្ញុំផ្លុំអង្គួចនៅ
ប្រាសាទ គាត់និយាយថា៖ «ចៅ! នេះហើយជា
អង្គួច។ ឧបករណ៍នេះមានតាំងពីបុរាណ។» ប៉ុន្តែ
ក្មេងៗសួរខ្ញុំថា៖ «បង! បងកាន់អ្វីហ្នឹង? តើវាជា
ប្រដាប់ជួសសំណាញ់មែនទេ?» ខ្ញុំប្រាប់ពួកគេថា៖
«មិនមែនទេ! វាជាអង្គួច។ គេប្រើវាសម្រាប់
លេងភ្លេង។» ខ្ញុំក៏ផ្លុំឲ្យគេស្ដាប់ ហើយគេក៏នាំគ្នា
សើច។ គេសប្បាយចិត្ត។»
**-ជី ចិន (រូបខាងលើ)**

*"Not many people know about Angkuoch any more. Most who do are old. When old people saw me playing at the temple, they said: 'Chao [grandchild]! This is Angkuoch. This instrument has existed since the era of our ancestors.' But younger people said, 'Brother! What are you holding? Is it a wooden pin to fix nets?' I told them: "No, it is an Angkuoch. People use it to make music." I played for them and they were happy."*
***–Chi Chen (above)***



ព្រឹទ្ធាចារ្យ ម៉ុង គើយ (កើតឆ្នាំ ១៩៣៧ ) ធ្លាប់ជាអ្នកធ្វើអង្គួចឫស្សីដ៏ល្បីឈ្មោះបំផុតម្នាក់ប្រចាំខេត្តសៀមរាប។ គាត់រស់នៅក្នុងភូមិព្រះដាក់ ដែលស្ថិតនៅមិនឆ្ងាយប៉ុន្មានពីភូមិរបស់ លោក ក្រាក់ ជី និងកូនៗរបស់គាត់។ ព្រឹទ្ធាចារ្យ ម៉ុង គើយ គឺជាមនុស្សដំបូងដែលធ្វើឱ្យកុមារ ចិន ស្គាល់អង្គួច ហើយក៏ជាមនុស្សម្នាក់ដែលបានបង្រៀនឪពុករបស់ លោក ចិន គឺលោក ក្រាក់ ជី ពីរបៀបធ្វើអង្គួច នៅពេលក្រោយមក។

កាលនៅពីក្មេង លោកតា គើយ បានរៀនវិជ្ជាធ្វើអង្គួចពីឪពុកគាត់។ ហើយគាត់បានលក់អង្គួច ដូង និងរបស់ផ្សេងៗទៀតទៅឱ្យភ្ញៀវទេសចរណ៍នៅតាមប្រាសាទនានាក្បែរភូមិគាត់ស្នាក់ប្រាស្រ័យ។ ក្រោយធំដឹងក្តី លោកតា គើយ ក៏បានក្លាយជាកសិករ និងជាជាងឈើទៀតផង។

លោកតា ម៉ុង គើយ បានរៀបការជាមួយប្រពន្ធទីពីររបស់គាត់ គឺលោកយាយ ឡាវ មិច (កើតឆ្នាំ ១៩៤៥ ) ក្នុងសម័យខ្មែរក្រហម។ គាត់បានចាប់ផ្តើមធ្វើអង្គួចសារជាថ្មីបន្ទាប់ពីការដួលរលំទៅនៃរបបឃ្មង់ឃ្មងនេះ។ ហើយចំណូលដែលគាត់រកបានពីលក់អង្គួច គឺសម្រាប់ផ្គត់ផ្គង់ដល់ការរៀនសូត្ររបស់កូនៗគាត់។

បើតាមសម្តីកូនស្រីគាត់ អ្នកនាង លក្ខិណា(រូបខាងឆ្វេង) បានឱ្យដឹងថា លោកយាយ មិច ក៏ធ្លាប់លេងអង្គួចឫស្សីដែរ កាលនៅពីក្មេង។ លោកយាយ មិច បានតំណាលប្រាប់រឿងប្តីគាត់ដល់យើងខ្ញុំថា ប្តីគាត់តែងនិយាយថា៖ «បងស្រឡាញ់អូន!» តាមរយៈការផ្ទាត់អង្គួចនេះឯង។

លោកតា ម៉ុង គើយ បានចែកឋាននៅវ័យប្រមាណ ៧០ ឆ្នាំ នៅក្នុងឆ្នាំ ២០១២ ។ ហើយកូនប្រុសទាំងបួននាក់របស់គាត់មានមោទកភាពក្រៃលែងដែលបានបន្តទំនៀមទម្លាប់ធ្វើអង្គួចមកទល់សព្វថ្ងៃ។

At one time, Mong Koeuy (born c.1937) was the best-known Angkuoch Russey maker in Siem Reap province. He lived in Preah Dak village, not far from where Krak Chi and his sons Chi Monivong and Chi Chen live. It was Ta Koeuy ("Grandpa Koeuy") who first introduced Angkuoch to the young Chen, and who later taught Chen's father Chi to make them.

As a child, Koeuy learnt to make Angkuoch from his father. He sold the instruments to tourists at the nearby temples, along with coconuts and other things. Later, as a young man, Koeuy also worked as a farmer and a carpenter.

Mong Koeuy married his second wife Lav Mech (b. 1945) during the Khmer Rouge era. He began selling Angkuoch again soon after the fall of the Khmer Rouge, and the income supported their children through school.

According to her daughter Leakhena (photo: back left), Mech also played Angkuoch Russey when she was younger. Mech told us that her husband spoke to her through the Angkuoch, which he used to tell her, "I love you".

Mong Koeuy passed away in his late 70s in 2012. Four of his sons are proud to continue their father's tradition.

«កាលពីដើម មនុស្សស្រីក៏និយាយតែតាមរយៈអង្គួចដែរ! មិនមែនមានតែមនុស្សប្រុសទេ! ពេលយប់ឡើង គេដើរលេង ហើយគេផ្ទាត់ថា «អូនស្រលាញ់បង!»។ សើច...! គេនិយាយតែតាមរយៈអង្គួច។»

**-ឡាវ មិច, ភរិយារបស់ ម៉ុង គើយ**

បើតាមគាត់ឪពុកខ្ញុំ គាត់ប្រាប់ខ្ញុំថា គាត់ចេះធ្វើអង្គួចតាំងពីពេលដែលគាត់ចេះកាន់កាំបិតមកម្លេះ។ មានន័យថា ពេលដែលគាត់អាយុដប់ឆ្នាំជាង ហើយគាត់ចាប់ផ្តើមកាន់កាំបិតបាន គាត់ក៏ចាប់ផ្តើមធ្វើតែម្តង។ ហើយដែលគាត់ចេះធ្វើនេះ គាត់មិនបានរៀនពីអ្នកណាទេ គឺគាត់រៀនពីជីតារបស់ខ្ញុំ។ ជីតារបស់ខ្ញុំឈ្មោះ ម៉ុង។ គាត់តែងប្រាប់ឪពុកខ្ញុំថា ពុកខ្ញុំត្រូវរៀនឱ្យចេះ ព្រោះវាជារបស់យើង។ »

**-គើយ រដ្ឋា (រូបខាងស្តាំ), កូនប្រុសរបស់ ម៉ុង គើយ**

*Before, women communicated through Angkuoch too, not only men. At night, they went for a walk and they played: 'I love you!' [Laughs...!] They communicated through Angkuoch.*

***-Lav Mech (photo: seated)***

*My father [Mong Koeuy] told me that he started to make Angkuoch when he could hold a knife. That means when he was about ten years old. He learned from no one but my grandpa, whose name is Mong. Grandpa Mong always told my father he must learn to make Angkuoch because it is our instrument.*

***-Koeuy Reatha (photo: back right)***



សារមន្ទីរនៃចក្រភពអង់គ្លេសមានអង្កួចតែមួយគត់នៅក្នុងសម្មុច្ច័យរបស់ខ្លួន ហើយជាឧបករណ៍ដែលគេមិនដឹងសោះឡើយថា នរណាជាអ្នកធ្វើ តែគេដឹងថាឧបករណ៍នេះត្រូវបានប្រគល់ឱ្យសារមន្ទីរនៅក្នុងឆ្នាំ ១៩៦៦ ។ នៅពេលដែលក្រុមអ្នកស្រាវជ្រាវបង្ហាញរូបថតអង្កួចដែលបានរក្សាទុកក្នុងសារមន្ទីរនោះទៅកាន់លោក ចិន និងលោក មុនីវង់ ក៏ដូចជាឪពុកពួកគាត់ លោក ក្រាក់ ជី អ្នកទាំងអស់គ្នាគិតថា ឧបករណ៍នេះមានលក្ខណៈស្រដៀងគ្នានឹងស្ទីលអង្កួចរបស់លោកតា ម៉ុង គើយ ជាពិសេសគឺ រូបរាង កម្រាស់ និងប្រវែង ក៏ដូចជាលក្ខណៈនៃថ្នាំងឫស្សីក្បែរអណ្ដាតរបស់ឧបករណ៍នេះ។

នៅពេលដែលពួកយើងបង្ហាញរូបភាពឧបករណ៍ ដែលគេរក្សាក្នុងសារមន្ទីរនៃចក្រភពអង់គ្លេស ដល់លោកយាយ មិច ដែលជាប្រពន្ធ និងអ្នកនាង លក្ខិណា និងលោក រដ្ឋា ដែលត្រូវជាកូនៗរបស់លោកតា ម៉ុង គើយ ពួកគេទាំងអស់គ្នាមានអារម្មណ៍រំជើបរំជួល។ ពួកគេចាំរូបរាងឧបករណ៍ដែលឪពុករបស់ពួកគេធ្វើច្បាស់ណាស់ ដោយសារតែពេលនោះ លោកតា គើយ បានលក់អង្កួចនេះយ៉ាងគគ្រឹកគគ្រេងឱ្យភ្ញៀវទេសចរណ៍ទាំងក្នុងស្រុក និងក្រៅស្រុក។ ដោយសារតែមានជំនួយការពីអ្នកធ្វើអង្កួច លោក គើយ រដ្ឋា ក្រុមអ្នកស្រាវជ្រាវកំពុងតែធ្វើការជាមួយសារមន្ទីរនៃចក្រភពអង់គ្លេស ដើម្បីបញ្ចូលព័ត៌មានអំពីប្រភពនៃឧបករណ៍នេះទៅក្នុងបញ្ជី។

The British Museum has only one Angkuoch in its collection, an instrument donated in 1966, of unknown maker. When the research team showed a photo of the Museum instrument to the brothers Chi Monivong and Chi Chen and their father Krak Chi, they all thought that the instrument bore strong resemblance to the unique style of Mong Koeuy, especially in its shape, thickness and length, as well as a characteristic node near the tongue of the instrument.

When we showed Mong Koeuy's wife Lav Mech and her children Leakhena and Reatha the photo of the British Museum instrument, they became emotional. They too recognised features of their father's instruments, which he had once sold widely to local and foreign tourists. With the help of Mong Koeuy's son, Angkuoch-maker Koeuy Reatha, the research team is working with the British Museum to include in its catalogue this new information about the likely provenance of the instrument.





«នៅពេលដែលខ្ញុំបានឃើញរូបភាពនោះ ខ្ញុំមានអារម្មណ៍រំភើបមែនទែន។ ខ្ញុំមិនដែលនឹកស្មានថាស្នាដៃរបស់គាត់បានផ្សព្វផ្សាយនៅថ្នាក់អន្តរជាតិសោះ។ ដោយសារសូម្បីតែនៅក្នុងស្រុក ក្មេងខ្លះមិនស្គាល់វាផង។ ដូចនេះ ខ្ញុំមិនដឹងថាវាមានតម្លៃដល់ថ្នាក់អន្តរជាតិ។ ពេលដែលខ្ញុំឃើញអង្គួចនេះ ខ្ញុំនឹកដល់គាត់។ សម្រាប់គ្រួសារខ្ញុំ អង្គួចដូចជាតំណាងឱ្យឪពុកខ្ញុំអ៊ីចឹង»។

**–គើយ លក្ខិណា, កូនស្រីរបស់ ម៉ុង គើយ**



*"When I first saw this photo [of the British Museum Angkuoch], I was very excited. I never knew my father's craft had been promoted internationally. Even locally, some people do not even know about it, so I had not thought it was very prized. Seeing this Angkuoch, I miss him. To my family, the Angkuoch symbolises my father."*

***–Koeuy Leakhena, daughter of Mong Koeuy***



## ក្រុមអ្នកស្រាវជ្រាវមាន៖


លោកស្រី ខាត់ធីរីន ហ្គ្រាន (អ្នកដឹកនាំគម្រោង)
លោក សុង សេង (ដៃគូសហការ)
លោក ប៉ាទ្រីក ឃើសសាឡេ (ដៃគូសហការ)
កញ្ញា សាយ តុលា (ជំនួយការគម្រោង)
លោក ថន ដីកា (អ្នកថតវីដេអូ)


## ស្ថាប័នសហការ៖

សាកលវិទ្យាល័យហ្គ្រីហ្វហ្វីធ
អង្គការសិល្បៈខ្មែរអមតៈ

រៀបរៀងកូនសៀវភៅនេះដោយ៖ ខាត់ធីរីន ហ្គ្រាន និង សុង សេង

បកប្រែជាភាសាខ្មែរដោយ៖ សាយ តុលា និង សុង សេង


គម្រោងស្រាវជ្រាវនេះឧបត្ថម្ភដោយ កម្មវិធីចំណេះដឹងអំពីសម្ភារៈដែលជិតបាត់បង់ របស់សារមន្ទីរនៃចក្រភពអង់គ្លេស និងគាំទ្រដោយ អាខាឌា ដែលជាមូលនិធិសប្បុរសធម៌របស់ លីសបែត រ៉ូស៊ីង និង ភីតធ័រ ប៊ែលវីន។

អង្គការយូណេស្កូប្រចាំប្រទេសកម្ពុជា ជួយគាំទ្រដល់ការផ្សព្វផ្សាយពីលទ្ធផលនៃគម្រោងនេះ ដោយធ្វើការបោះពុម្ពផ្សាយនិង ចែកចាយកូនសៀវភៅនេះ។

ក្រុមអ្នកស្រាវជ្រាវក៏សូមអរគុណដល់អាជ្ញាធរជាតិអប្សរា និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សម្រាប់ការគាំទ្រ។


បើលោកអ្នកចង់ស្វែងរកវីដេអូឯកសារ និងឯកសារផ្សេងៗទាក់ទងនឹងគម្រោងនេះ សូមអញ្ជើញចូលទៅកាន់គេហទំព័រ៖ www.emkp.org ឬ https://preview.tinyurl.com/bm-diimcmh


សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង បណ្ឌិត ខាត់ធីរីន ហ្គ្រាន ៖

Catherine.Grant@griffith.edu.au



CC BY NC SA


## Project team:


Dr Catherine Grant (project leader)
Mr Seng Song (collaborator)
Mr Patrick Kersale (collaborator)
Ms Say Tola (research assistant)
Mr Thon Dika (videographer)


## Institutional partners:

Griffith University
Cambodian Living Arts

Brochure text by Catherine Grant and Song Seng

Translation by Say Tola and Song Seng


This project was funded by the British Museum's Endangered Material Knowledge Programme, supported by Arcadia, a charitable fund of Lisbet Rausing and Peter Baldwin.

UNESCO (Cambodia) provided additional funding for dissemination of outcomes, including for the printing and distribution of this brochure.

The project team also acknowledges the support of the Apsara National Authority and the Ministry of Culture and Fine Arts, Royal Government of Cambodia.


To access the video documentary and other project materials, visit www.emkp.org or https://preview.tinyurl.com/bm-diimcmh


For further information, contact Dr Catherine Grant: Catherine.Grant@griffith.edu.au



United Nations Educational, Scientific and Cultural Organization
In partnership with UNESCO
សិល្បៈខ្មែរអមតៈ CAMBODIAN LIVING ARTS
Griffith UNIVERSITY Queensland, Australia
EMKP ENDANGERED MATERIAL KNOWLEDGE PROGRAMME



